**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០១ឆក.......**

# ផែនការ

## ស្តីពី

## យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤

## រយៈពេល ០១ឆ្នាំ (ចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩)

ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនលើកទី៣ រយៈពេល ០១ឆ្នាំ(ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨) របស់រាជរដ្ឋាភិបាល ត្រូវបានចាត់តាំងអនុវត្តយ៉ាងសកម្មផុលផុស ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់ស្រទាប់ប្រជាពលរដ្ឋ មន្ត្រីរាជការ និងមហាជនក្នុងសង្គម ដែលបង្កើតបានជាចលនាជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងមានការគាំទ្រ និងកោតសរសើរពីសំណាក់មជ្ឈដ្ឋានជាតិ អន្តរជាតិ ចំពោះស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល លើជោគវាសនាប្រទេសជាតិ និងប្រជាពលរដ្ឋផងដែរ។

វិធានការគន្លឹះទាំង៥ ដែលជាផែនទីបង្ហាញផ្លូវក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានដំណើរការយ៉ាងសកម្ម ជាពិសេសការអនុវត្តវិធានការច្បាប់ទទួលបានលទ្ធផលខ្ពស់ ដោយសមត្ថកិច្ចពាក់ព័ន្ធបានបើកប្រតិបត្តិការយ៉ាងក្តៅគគុក បង្ក្រាបការជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ចំនួន ៨.០០២ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៦.២១៦នាក់ និងសារធាតុញៀនចាប់យកគ្រប់ប្រភេទសរុប ៥៣៦,៣៦គ.ក្រ រួមទាំងមធ្យោបាយ សម្ភារ វត្ថុតាងមួយចំនួន។ ក្នុងនោះ សមត្ថកិច្ចបានបង្ក្រាបចាប់ខ្លួនមេក្លោង និងកាត់ផ្តាច់ខ្សែរយៈបណ្តាញជួញដូរគ្រឿងញៀនធំៗ ចំនួន ៤៧ករណី ដោយបានចាប់ឃាត់ខ្លួនចំនួន ៨៣នាក់ យកមកផ្តន្ទាទោសតាមច្បាប់។ ដោយឡែក តាមរយៈកិច្ចប្រតិបត្តិការវាយឆ្មក់ដកពិសោធន៍ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់តាមទីតាំងសប្បាយដ្ឋាននៅគោលដៅអាទិភាពមួយចំនួន (រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប) បានផ្តល់ពិសោធន៍ល្អៗ ក្នុងប្រតិបត្តិការបង្រ្កាមទីផ្សារជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅក្នុងប្រទេស ហើយក៏ជាសក្ខីកម្មឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងអនុវត្តច្បាប់ ក្នុងការលើកកម្ពស់ស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់ទូទៅនៅមូលដ្ឋានភូមិ-ឃុំ ឲ្យកាន់តែល្អប្រសើរជាងមុន។

លទ្ធផលនៃការបង្ក្រាបខាងលើនេះ បានធ្វើឲ្យបទល្មើសឧក្រិដ្ឋមួយចំនួនមានការថយចុះ ដូចជាអំពើប្លន់ និងឃាតកម្ម ដែលស្ថានភាពបែបនេះបានជះឥទ្ធិពលជាវិជ្ជមានដល់បរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់ជាទូទៅ ជាពិសេស ការបង្ក្រាបឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន និងការបន្សាបព្យាបាលអ្នកប្រើប្រាស់សារធាតុញៀន បានកាត់បន្ថយក្តីបារម្ភរបស់ប្រជាពលរដ្ឋអំពីបញ្ហាសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងមូលដ្ឋាន ក៏ដូចជាជួយស្រោចស្រង់អនាគតយុវវ័យ និងបង្កើនភាពកក់ក្តៅដល់អាណាព្យាបាល ឬក្រុមគ្រួសាររបស់ពួកគេផងដែរ។

អាស្រ័យដោយនិន្នាការនៃការផលិត ការចរាចរ និងការជួញដូរគ្រឿងញៀនខុសច្បាប់នៅក្នុងតំបន់ និងលើពិភពលោក នៅតែមានកំណើន និងនៅតែបន្តជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ដល់កម្ពុជា ជាពិសេសការលេចចេញនូវរូបភាព និងទ្រង់ទ្រាយថ្មីៗ នៃការលួចនាំចូលសារធាតុញៀនមកកម្ពុជា ដូចជាកំណើននៃការនាំចូលតាមព្រលានយន្តហោះ និងតាមបញ្ញើប្រៃសណីយ៍ ដែលសកម្មភាពទាំងនេះ ទាមទារឲ្យមានវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឲ្យកាន់តែសកម្ម និងក្តៅគគុកបន្ថែមទៀត។ ស្ថិតក្នុងបរិបទនេះ រាជរដ្ឋាភិបាលសម្រេចបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ **លើកទី៤ រយៈពេល ០១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែមករា រហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩** ដូចខាងក្រោម ៖

## I. គោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពនូវបទបញ្ជាលេខ ០១ ប.ប ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ចាត់តាំងអនុវត្តយុទ្ធនាការលើកទី៤ ដោយផ្អែកតាមគោលការណ៍រួម និងវិធានការទាំង៥ ដែលបានកំណត់ក្នុងផែនការយុទ្ធនាការលើកទី១ និងវិធានការនៃយុទ្ធនាការលើកទី២ និងទី៣
- ពិនិត្យកែសម្រួលឡើងវិញ នូវសមាសភាពមួយចំនួននៅក្នុងយន្តការនៃយុទ្ធនាការលើកទី៣ ដើម្បីប្រើប្រាស់ជាយន្តការសម្រាប់អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤។

## II. វិធានការ

បន្តជំរុញការអនុវត្តវិធានការទាំង ៥ ដែលមានចែងក្នុងផែនការយុទ្ធនាការលើកទី១ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត គួបផ្សំនឹងវិធានការនៃយុទ្ធនាការលើកទី២ និងលើកទី៣ ដើម្បីធ្វើជាមូលដ្ឋានចាត់តាំងអនុវត្ត ដោយត្រូវខិតខំធ្វើឲ្យបានសម្រេចនូវការងារសេសសល់ក្នុងយុទ្ធនាការលើកទី៣ និងត្រូវប្រមូលផ្តុំយកចិត្តទុកដាក់លើការងារចម្បងៗ ជាអាទិភាពដូចតទៅ ៖

១.ត្រូវខិតខំបង្កើនសកម្មភាពអនុវត្តវិធានការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋទូទៅ ពិសេសត្រូវយកចិត្តទុកដាក់ផ្តោតការអប់រំឲ្យចំគោលដៅ និងមុខសញ្ញាងាយរងគ្រោះ ឲ្យយល់ដឹងកាន់តែទូលំទូលាយ និងស៊ីជម្រៅអំពីគ្រោះថ្នាក់ និងផលអវិជ្ជមានដែលបណ្តាលមកពីគ្រឿងញៀន ព្រមទាំងអំពាវនាវដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ គ្រប់មជ្ឈដ្ឋាន ឲ្យចូលរួមក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន និងការពារសុខុមាលភាពសង្គម។

២.ជំរុញសកម្មភាពរៀបចំវេទិកាជួបជាមួយវិស័យឯកជន និងសប្បុរសជន ជាពិសេសម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មដែលអាចងាយរងហានីភ័យដោយសារគ្រឿងញៀន និងសិល្បៈករ សិល្បៈការិនី បណ្តាញសារព័ត៌មាន អ្នកដឹកនាំសាសនា ព្រមទាំងអង្គការ សង្គមស៊ីវិល នៅគ្រប់រាជធានី-ខេត្ត រហូតដល់មូលដ្ឋាន សំដៅប្រមូលផ្តុំឲ្យមានការចូលរួមសហការគាំទ្រទាំងសកម្មភាព និងមូលនិធិ ក្នុងចលនាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៣.ពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ឲ្យបានហ្មឺងម៉ាត់ សំដៅបង្រួមទីផ្សារជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដោយត្រូវយកចិត្តទុកដាក់ចំពោះគោលដៅដែលងាយទទួលរងហានីភ័យដោយសារ ឬកើតមានការជួញដូរ ការប្រើប្រាស់គ្រឿងញៀន ពិសេសត្រូវដកស្រង់បទពិសោធន៍ដែលបានបើកប្រតិបត្តិការនៅប៉ូលទេសចរណ៍ទាំង០៣ (ភ្នំពេញ-សៀមរាប-ព្រះសីហនុ)នាពេលកន្លងមក ដោយកំណត់ឲ្យបានជាក់លាក់នូវភូមិសាស្រ្ត និងគោលដៅអាទិភាព ព្រមទាំងមានកម្មវិធីការងារសម្រាប់អនុវត្តកិច្ចការនេះច្បាស់លាស់ជាប្រចាំ។ ចំពោះបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង ត្រូវខិតខំកសាងភូមិ-ឃុំ សង្កាត់ ស គ្មានគ្រឿងញៀនយ៉ាងតិច ១គោលដៅ **(លើកលែងបណ្តាខេត្តជាប់ព្រំដែននៅភូមិភាគឦសាន្ត ត្រូវខិតខំពង្រីកវិសាលភាពបន្ថែមទៀត)**។

៤.ជំរុញការរិះរកនីតិវិធីក្នុងការចាត់ចែងវត្ថុតាង និងទ្រព្យសម្បត្តិនានា ដែលត្រូវបានរឹបអូស និងបង្កក ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនឲ្យបានឆាប់រហ័ស ដើម្បីយកមកគាំទ្រក្នុងសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៥.ជំរុញកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ជាពិសេសបន្តខិតខំទប់ស្កាត់ការនាំចូលពីក្រៅប្រទេស និងស្រាវជ្រាវនូវបណ្តាញខ្សែរយៈឧក្រិដ្ឋជនជួញដូរគ្រឿងញៀនធំៗ ដើម្បីបង្ក្រាបឲ្យដល់ឫសគល់ ព្រមជាមួយនឹងការយកចិត្តទុកដាក់ក្នុងការថែបំប៉ន និងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅធ្វើឲ្យប្រតិបត្តិការបង្ក្រាបគ្រឿងញៀនខុសច្បាប់ កាន់តែមានប្រសិទ្ធភាពខ្ពស់។

៦.បន្តពង្រឹង និងជំរុញសកម្មភាពអនុវត្តវិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ដោយត្រូវមានយន្តការដឹកនាំ និងសម្របសម្រួលច្បាស់លាស់នៅថ្នាក់ឃុំ-សង្កាត់ ជាមួយគ្នានេះ ត្រូវខិតខំលើកកម្ពស់សមត្ថភាព គុណភាព និងពង្រីកសេវាបន្សាបព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់គោលដៅអាទិភាព ឈានទៅពង្រីកវិសាលភាពគ្របដណ្តប់បាន ២៥% ឃុំ-សង្កាត់នៅទូទាំងប្រទេស និងត្រូវជំរុញការងារសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ឲ្យបានរួចរាល់ ព្រមទាំងបន្តកសាងមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទា តាមរាជធានី-ខេត្ត ដែលមានអំណោយផល។

៧.កសាងឲ្យបាននូវយន្តការតាមដាន ត្រួតពិនិត្យមុខសញ្ញាប្រើប្រាស់សារធាតុញៀន មុខសញ្ញាដែលបានសមាហរណកម្មចូលក្នុងសហគមន៍ ដើម្បីគ្រប់គ្រង និងមានវិធានការក្នុងការបង្ការ ទប់ស្កាត់មិនឲ្យពួកគេវិលត្រឡប់មកប្រើប្រាស់សារធាតុញៀនវិញ។

III. **ការចាត់តាំងអនុវត្ត**

១.គណៈបញ្ជាការដឹកនាំយុទ្ធនាការលើកទី៤ នេះគឺ ៖

- **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាប្រធានយុទ្ធនាការ**

- ឯកឧត្តម **នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ជាអនុប្រធានយុទ្ធនាការ**

- ប្រគល់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលដឹកនាំផ្ទាល់លើការងារផ្សព្វផ្សាយអប់រំ និងការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវយន្តការអនុវត្តឲ្យស្របតាមស្មារតីនៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤។

២.ផ្អែកលើផែនការនេះ គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ យន្តការចំណុះទាំងអស់ រួមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ត្រូវកសាងផែនការជាក់ស្តែង សម្រាប់ចូលរួមអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួន។

៣.ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន និងមានវិធានការអនុវត្តវិន័យហ្មឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់៕

ថ្ងៃ អង្គារ ១៤ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**